# ការអប់រំសម្រាប់កូនៗរបស់យើងទាំងអស់គ្នា ៖ ការទទួលយកជាតិសាសន៍ចម្រុះ

## សេចក្តីសង្ខេប


Aotearoa New Zealand ជាកន្លែងមានភាពចម្រុះជាតិសាសន៍ ហើយកំពុងក្លាយ ទៅជាស្ថានភាព នេះយ៉ាងឆាប់រហ័ស ។ នៅតាមសាលាទូទាំងប្រទេស សិស្សរបស់យើងកាន់តែច្រើនគឺមកពីសហគមន៍ ជនភាគតិច ។ នៅឆ្នាំ 2043 គេរំពឹងថានឹងមានសិស្ស ច្រើនជាងមួយនាក់ ក្នុងចំណោមបួននាក់ នៅ New  Zealand គឺជាអ្នកមកពីសហគមន៍ជនជាតិ ។ នៅទីក្រុង Auckland គេរំពឹងថា នឹងមានសិស្ស ច្រើនជាង 2 នាក់ក្នុងចំណោម 5 នាក់ គឺជាជនជាតិអាស៊ី ។

គឺជារឿងសំខាន់ដែលការអប់រំត្រូវ សមទៅតាមតម្រូវការ កូនចៅរបស់យើងទាំងអស់គ្នា ។ ការសិក្សា នេះ មានគោលបំណង ដើម្បីពិនិត្យ មើល ថាតើ ការអប់រំរបស់យើង ត្រូវធ្វើបែបណា ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សិស្សដែលមកពីសហគមន៍ជនភាគតិច ។ លទ្ធផល បានបង្ហាញថា សិស្សមួយចំនួនធំ ដែលមកពីសហគមន៍ជនភាគតិច ទទួលបានលទ្ធផលល្អក្នុងការសិក្សា ។ សិស្សមកពីសហគមន៍ជនភាគតិច ទំនងជាទទួលបានលទ្ធផលល្អ ក្នុងកម្មវិធី NCEA ហើយ បន្តទៅរៀននៅសកលវិទ្យាល័យ ។

ប៉ុន្តែការសិក្សានេះក៏បានរកឃើញដែរថា សិស្សមកពីសហគមន៍ជនជាតិភាគតិច កំពុងជួបប្រទះនឹងការរើសអើងជាតិសាសន៍, ភាពឯកោ និងកង្វះការយល់ដឹងអំពីវប្បធម៌ ។ លទ្ធផល ក៏បាន បង្ហាញដែរថា ការអប់រំ មិនមែនជានិច្ចកាល សុទ្ធតែឆ្លុះបញ្ចាំង ចំពោះអ្វីដែលពលរដ្ឋ មកពីសហគន៍ជនភាគតិច នៅប្រទេសនូវេស៊ីឡង់ ត្រូវការដែរ ។

ខណៈពេលដែល សាលារៀន នៅប្រទេសនូវេស៊ីឡង់ កាន់តែមានភាពចម្រុះជាតិសាសន៍ ពេលនេះ គឺជាឱកាសដ៏រំភើប ក្នុងការពិនិត្យមើលជាថ្មីម្តងទៀត អំពីអ្វីដែលយើងបង្រៀន និងរបៀបដែល យើងបង្រៀន ដល់សិស្សទាំងនោះ ។ សាលារៀនជាច្រើនកំពុងផ្លាស់ប្តូរដើម្បីត្រៀមខ្លួនទទួលយក សិស្សចម្រុះជាតិសាសន៍ ប៉ុន្តែនឹងត្រូវការឲ្យមានការផ្លាស់ប្តូរច្រើន ជាងនេះទៀត ។ របាយការណ៍នេះរួមបញ្ចូលនូវជម្រើស សម្រាប់ការផ្លាស់ប្តូរដើម្បីធ្វើឱ្យ Aotearoa New Zealand ក្លាយជាកន្លែងដ៏ល្អមួយ របស់កុមារ  និងយុវជនរបស់យើង មកពីសហគមន៍ជនជាតិភាគតិច សម្រាប់ការរៀនសូត្រ ។


**ការសិក្សានេះ គឺជាការសង្ខេបទស្សនៈ រយៈពេលវែង**

ការសង្ខេបអំពី ទស្សនៈរយៈពេលវែង អាចជួយយើងបាន ក្នុងការកំណត់ និងស្វែងរក បញ្ហាដែលមានសារៈសំខាន់ សម្រាប់សុខុមាលភាពនាពេលអនាគត របស់មនុស្សនៅ Aotearoa នូវេស៊ីឡង់ ។ ទស្សនៈរយៈពេលវែងនេះ អាចផ្តល់ព័ត៌មានអំពីនិន្នាការរយៈពេលមធ្យម និងរយៈពេលវែង, ហានិភ័យ និងឱកាស, និងស្វែងរកជម្រើសអំពីរបៀបដែលល្អបំផុត សម្រាប់ឆ្លើយតបចំពោះស្ថានភាពទាំងអស់នោះ ។

ការិយាល័យពិនិត្យការអប់រំ (Education Review Office), សហការជាមួយក្រសួងសហគមន៍ជនភាគតិច (Ministry for Ethnic Communities), ចង់ស្វែងយល់ពីបទពិសោធន៍អប់រំរបស់ សិស្សមកពីសហគមន៍ជនជាតិភាគតិច និង ទំនាក់ទំនងក្រុមគ្រួសារធំ របស់ពួកគេ ។[1]

## តើអ្វីជាភាពចម្រុះជាតិសាសន៍?

មានទម្រង់នៃភាពចម្រុះជាតិសាសន៍ជាច្រើន រួមមាន ជនជាតិ, វប្បធម៌, ភាសា, យេនឌ័រ, អត្តសញ្ញាណផ្លូវភេទ និង ភាពចម្រុះខាងសាសនា ។ សម្រាប់ការសិក្សានេះ យើងខ្ញុំបានផ្តោតលើភាពចម្រុះជាតិសាសន៍ និងភាសាដែលពាក់ព័ន្ធ វប្បធម៌ និងសាសនា ។ ជនជាតិភាគតិច ត្រូវគេកំណត់ថាជាក្រុមជនភាគតិច ដែលមនុស្សចាត់ទុកថាជា អត្តសញ្ញាណរបស់ពួកគេ ឬនឹងថាខ្លួនជាផ្នែកមួយនៃក្រុមនេះ ។ សហគមន៍ជនជាតិភាគតិច ដែលរួមបញ្ចូលក្នុង របាយការណ៍នេះ គឺអាហ្វ្រិក, អាស៊ី, អាមេរិកឡាទីន និងមជ្ឈិមបូព៌ា ។[2]

## តើសិស្សទាំងអស់នេះជានរណា?

**សិស្ស ដែលមកពីសហគមន៍ជនភាគតិច គឺមានភាពចម្រុះជាតិសាសន៍ច្រើន** ដោយពួកគេមានជាតិពន្ធ, សាសនា, វប្បធម៌, ពេលវេលារស់នៅក្នុងប្រទេសនូវែស៊ីឡង់ និងប្រវត្តិគ្រួសារ ខុសៗគ្នា ។ ជាងពីរភាគបីនៃសិស្ស មកពី សហគមន៍ជនភាគតិច ជាមនុស្សដែលកើតនៅលើទឹកដី នៃប្រទេសនូវស៊ីឡង់ ។ សិស្ស ជាច្រើនមានជាតិពិន្ទុច្រើន ហើយជាងពាក់កណ្តាលនៃមនុស្សមកពីសហគមន៍ជនភាគតិចចេះនិយាយច្រើនភាសា ។

## តើភាពចម្រុះជនជាតិភាគតិច មើលទៅដូចអ្វីនៅក្នុងសាលារៀន Aotearoa New Zealand ដែរឬទេ ហើយតើវាផ្លាស់ប្តូរយ៉ាងដូចម្តេច ?

### Aotearoa New Zealand មានភាពចម្រុះជាតិសាសន៍ ហើយរឿងនេះកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សដែរ

ភាពចម្រុះជាតិសាសន៍ កំពុងកើនឡើងនៅទូទាំងប្រទេស ប៉ុន្តែភាគច្រើន មានការកើនឡើងយ៉ាងឆាប់រហ័សនៅ ក្នុងតំបន់ទីក្រុង ។ សិស្សទាំងឡាយ គឺជាមនុស្សមកពីសហគមន៍ជនភាគតិចផ្សេងៗជាច្រើន ។ នៅឆ្នាំ 2043 គេរំពឹងថា នឹងមានតែសិស្សមួយនាក់ទេ ក្នុងចំណោមសិស្សបួននាក់ (26 ភាគរយ) មានអត្តសញ្ញាណជនជាតិអាស៊ី ហើយប្រហែលជាមួយនាក់ ក្នុងចំណោមសិស្ស 20 នាក់ (3.6 ភាគរយ) មានអត្តសញ្ញាណជាជនជាតិមជ្ឈិមបូព៌ា, អាមេរិកឡាទីន ឬអាហ្វ្រិក (MELAA) ។ នៅទីក្រុង Auckland សិស្សច្រើនជាង 2 នាក់ក្នុងចំណោមសិស្ស 5 នាក់ (43 ភាគរយ) មានអត្តសញ្ញាណជាជនជាតិអាស៊ី ។

***រូបភាពទី 1៖** សមាមាត្រនៃសិស្ស (អាយុ 5 ដល់ 19 ឆ្នាំ) នៅ Aotearoa New Zealand ដែលមានអត្តសញ្ញាណ ជា MELAA ឬអាស៊ី*

[1] “Whānau” សំដៅលើឪពុកម្តាយ/អ្នកថែទាំ និងសាច់ញាតិ របស់សិស្សទាំងនេះ ដើម្បីទទួលស្គាល់សារៈសំខាន់នៃទំនាក់ទំនងជិតស្និទ្ធ និងផ្សារភ្ជាប់របស់ពួកគេ ។

[2] ពាក្យថា 'ជនភាគតិច' សំដៅលើមនុស្សដែលកំណត់អត្តសញ្ញាណខ្លួនឯងថាជា អ្នកមកពីមជ្ឈិមបូព៌ា, អាមេរិកឡាទីន, អ្នកមក ពីទ្វីបអឺរ៉ុប, អាស៊ី ឬអាហ្វ្រិក ។ ដោយសារការឆ្លើយតបចំពោះការស្ទង់មតិរបស់យើងខ្ញុំ និងទិន្នន័យដែលមាន, ដូច្នេះ យើងខ្ញុំមិន បានរាប់បញ្ចូលបទពិសោធន៍របស់សិស្ស នៅទ្វីបអឺរ៉ុបនៅក្នុងរបាយការណ៍នេះទេ ។




ស្ថិតិ NZ ,នៃជំរឿន 2013 និង 2018, ក្រុមជនភាគតិច (សម្រាប់ឆ្នាំ 2013 និង 2018); និងការព្យាករណ៍ចំនួនប្រជាជនជាជនភាគតិច ៖ 2018 (ទិន្នន័យមូលដ្ឋាន)–2043, ការព្យាករណ៍ជាមធ្យម (សម្រាប់ ឆ្នាំ 2043) ។

| | |
|---|---|
| Asian | អាស៊ី |
| MELAA (Middle Eastern, Latin American and African) | មជ្ឈិមបូព៌ា, អាមេរិកឡាទីន និងអាហ្វ្រិក |

### ***រូបភាពទី 2 ៖*** *សមាមាត្រនៃសិស្ស (អាយុ 5 ដល់ 19 ឆ្នាំ) ក្នុងតំបន់ដែល មានអត្តសញ្ញាណជាជនជាតិអាស៊ី*




ប្រភព ៖ ស្ថិតិនូវេស៊ីឡង់ដ៍, ជំរឿន 2018, ក្រុមជនជាតិភាគតិច (សម្រាប់ឆ្នាំ 2018) និង ការទស្សន៍ទាសមូលដ្ឋានចំនួប្រជាជនថ្នាក់ក្រោមជាតិ 2018-(សម្រាប់ឆ្នាំ 2043) ការទស្សន៍ទាយចំនួនមធ្យម (សម្រាប់ឆ្នាំ 2043) ។

| | |
|---|---|
| The Asian population is expected to increase in schools across the country | ប្រជាជនអាស៊ីត្រូវបានគេរំពឹងថានឹងកើនឡើងនៅក្នុងសាលារៀនទូទាំងប្រទេស |
| Auckland | អូកឡិន |
| Bay of Plenty | Bay of Plenty |
| Waikato | Waikato |
| Wellington | Wellington |
| Nelson | Nelson |
| Canterbury | Canterbury |
| Southland | តំបន់ចុងកោះខាងត្បូង (Southland) |

## តើអ្វីខ្លះដែលសិស្សបានជួបប្រទះអំពីការអប់រំមកពីសហគមន៍ចម្រុះជនភាគតិច និង whānau របស់ពួកគេ?

### 1. សិស្សជាច្រើន ដែលមកពីសហគមន៍ជនជាតិភាគតិច សម្រេចលទ្ធផលការអប់រំបានល្អ

បើគេក្រឡេកមើលលើ វិញ្ញាបនបត្រជាតិនៃសមិទ្ធិផលអប់រំ (NCEA), សមិទ្ធិផល និងការទទួលស្គាល់ គឺសិស្សជាជនជាតិអាស៊ី មានចំនួនខ្ពស់ជាង ចំនួនមធ្យមរបស់នូវេស៊ីឡង់ដ៍, ហើយទាំងសិស្ស MELAA និងសិស្សអាស៊ីទំនងជាអាចសម្រេចបានច្រើនជាង ក្នុងការប្រឡងចូល និងចូលរៀននៅសកលវិទ្យាល័យ ។ ទោះជាយ៉ាងណាក៏ដោយគឺមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងនៅទូទាំងសហគមន៍ជនភាគតិច, ហើយនៅក្នុងសហគមន៍ជនភាគតិចទាំងអស់ក៏មានសិស្ស ដែលរៀនមិនសូវពូកែដែរ ។

***រូបភាពទី 3 ៖** ការទទួលស្គាល់គុណសម្បត្តិ និងឧត្តមភាព នៃ NCEA កម្រិត 2, តាមជនជាតិ ៖ 2021*




ប្រភព៖ NZQA, ភាពជោគជ័យនៃ NCEA កម្រិត 1, 2 និង 3 ជនភាគតិច, ឆ្នាំ 2021

### 2. សិស្សមកពីសហគមន៍ជនភាគតិច បានជួបប្រទះការគម្រាមកំហែងការរើសអើងជាតិសាសន៍ ដែលកំពុងតែរីករាលដាល ហើយដែលជាធម្មតា សាលាមិនសូវយកចិត្តទុកដាក់ដោះស្រាយឡើយ

សិស្សចំនួនមួយនាក់ ក្នុងចំណោមសិស្សប្រាំនាក់ មកពីសហគមន៍ជនជាតិភាគតិច បានជួបប្រទះការសម្លុតរើសអើងពូជសាសន៍កាលពីខែមុន ហើយជាងពាក់កណ្ដាលបានឃើញអ្នកផ្សេងទៀតត្រូវបានគេធ្វើបាបដោយសារតែពួកគេជាជនជាតិភាគតិច ។ ទាំង whānau និងសិស្ស បានរាយការណ៍ថា អំពើសម្លុតរើសអើងជាតិសាសន៍ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់ និងដោះស្រាយឱ្យបានប្រសើរជាងមុននៅសាលា ។ ជិតមួយភាគបីនៃសិស្ស ដែលមកពីសហគមន៍ជនភាគតិច គិតថា សាលារបស់ពួកគេ មិនយកចិត្តទុកដាក់ខ្លាំងលើបញ្ហាវាយប្រហារលើជាតិសាសន៍ ។

*រូបទី 4 ៖: បទពិសោធន៍របស់សិស្ស អំពីបញ្ហាវាយប្រហារជាតិសាសន៍ និងការរើសអើងជាតិសាសន៍កាលពី 30 ថ្ងៃកន្លងទៅ*[3]




ប្រភព ៖ ការស្ទង់មតិសិស្ស ERO, ឆ្នាំ 2022

*"ខ្ញុំនៅមានអារម្មណ៍ដូចជារឿងចម្លែកក្នុងការយកអាហារឥណ្ឌាមកសាលា ដោយសារតែយើងត្រូវញ៉ាំវាដោយប្រើដៃ ។ មានមិត្តភក្តិរបស់ខ្ញុំម្នាក់—នាងជាជនជាតិឥណ្ឌា, នាងត្រូវបានគេធ្វើបាបយ៉ាងខ្លាំង ដោយសារតែអាហាររបស់នាង ហើយនាងបានក្លាយជាមនុស្សឯកោ ។ ហើយនាងបានព្យាយាមយកនំសាំងវិចមកសាលា បើទោះបីជានាងមិនចូលចិត្តញ៉ាំវាក៏ដោយ, ប៉ុន្តែវាយឺតពេលហើយសម្រាប់នាង» ។ (សិស្ស)*

## 3. ជាទូទៅ សិស្សមកពីសហគមន៍ជនជាតិភាគតិច មានអារម្មណ៍ថាខ្លួនមិនមែនជាផ្នែកមួយនៃបរិស្ថានការសិក្សាឡើយ

សិស្ស ស្ទើរតែមួយនាក់ ក្នុងចំណោមសិស្សប្រាំនាក់ មកពីសហគមន៍ជនជាតិភាគតិច បានរាយការណ៍ថា ពួកគេតែងតែមានអារម្មណ៍ថាពួកគេមិនមែនជាផ្នែកមួយរបស់សាលា ហើយសិស្សទីបី មានអារម្មណ៍ឯកោនៅសាលារៀនរៀងរាល់សប្តាហ៍ ឬជារៀងរាល់ថ្ងៃ ។ សិស្សស្ទើរតែមួយនាក់ ក្នុងចំណោមសិស្សប្រាំនាក់ ក៏មានអារម្មណ៍ថា ពួកគេត្រូវតែលាក់អត្តសញ្ញាណជនជាតិរបស់ពួកគេនៅសាលារៀន ឬមានអារម្មណ៍ថាត្រូវបានដកចេញពីសកម្មភាពសាលាដោយសារតែអត្តសញ្ញាណជនជាតិរបស់ពួកគេ ។ សិស្ស MELAA ជាពិសេស មានសុខុមាលភាពទាបខ្លាំង ។

*"ខ្ញុំមានអារម្មណ៍ថា គឺមានពេលតែមួយគត់ដែលអ្នកអាចបង្ហាញវប្បធម៌របស់ខ្លួនបាន គឺនៅក្នុងសប្តាហ៍វប្បធម៌" ។ (សិស្ស)*

## 4. ការអប់រំដែលផ្តល់ជូន មិនតែងតែឆ្លុះបញ្ចាំងពីអ្វីដែល whānau និងសិស្ស មកពីសហគមន៍ជនភាគតិចចង់បាននោះទេ

នៅពេលដែល Aotearoa New Zealand មានការផ្លាស់ប្តូរ, អ្វីដែលសហគមន៍ចង់បានពីការអប់រំ ក៏ផ្លាស់ប្តូរផងដែរ ។ បច្ចុប្បន្នការអប់រំមិនតែងតែឆ្លុះបញ្ចាំង ពីអ្វីដែលសហគមន៍ជនជាតិភាគតិច ចង់បាននោះទេ ។ បួននាក់ក្នុងចំណោម 10 whānau និងជិតមួយភាគបីនៃ សិស្ស មកពីសហគមន៍ជនភាគតិច យល់ថា កិច្ចការសាលាដែលគ្រូដាក់ឲ្យ មិនសូវពិបាកធ្វើទេ ។ ស្ទើរតែពីរភាគបីនៃ whānau យល់ថាសាលា គួរតែគាំទ្រភាសាកំណើតរបស់ពួកគេ, ប៉ុន្តែមានភាសាជនជាតិភាគតិចចំនួន 11 រួមទាំងភាសាហិណ្ឌូ ដែលជាភាសានិយាយច្រើនជាងគេទីបួននៅក្នុង Aotearoa ដែលមិនមាននៅក្នុងការប្រឡង NCEA ឡើយ ។ Wānau ខ្លះ ក៏ចង់ឱ្យសាលាបង្រៀនសាសនា ឲ្យបានច្រើន ផងដែរ ។

[3] ភាគរយសរុប នៃការឆ្លើយតបគឺច្រើន 100 ភាគរយ ដោយសារអ្នកឆ្លើយតបទាំងអស់ អាចជ្រើសរើសចម្លើយច្រើនជាងមួយ ។

### 5. Whānau មកពីសហគមន៍ជនជាតិភាគតិច ក៏ជួបឧបសគ្គក្នុងការចូលរួមសកម្មភាពសាលាដែរ

Whānau មកពីសហគមន៍ជនភាគតិច ចង់ចូលរួមជាផ្នែកមួយ ក្នុងសកម្មភាពអប់រំរបស់កូនរបស់ពួកគេ ។ ពួកគេចូលរួមសកម្មភាពប្រជុំព័ត៌មានមាតាបិតាសិស្សច្រើនជាងសកម្មភាពផ្សេងទៀត ប៉ុន្តែមិនទទួលបានព័ត៌មានអំពីការសិក្សារបស់កូនពួកគេមិនគ្រប់គ្រាន់ឡើយ ឬក៏មានការភ័ន្តច្រឡំ អំពីព័ត៌មានការសិក្សានៃកូនរបស់ពួកគេ ។ ពួកគេមានអ្នកតំណាងមិនគ្រប់គ្រាន់នៅក្រុមប្រឹក្សាសាលា -ឧទាហរណ៍ មានឪពុកម្តាយសិស្សតែ 2 ភាគរយប៉ុណ្ណោះ នៅក្នុងក្រុមប្រឹក្សាសាលា ដែលជាជនជាតិអាស៊ី ។

### 6. សិស្សជាច្រើនមកពីសហគមន៍ជនជាតិភាគតិច បន្តការសិក្សាថ្នាក់ឧត្តមសិក្សា ប៉ុន្តែព័ត៌មានសម្រាប់ការសម្រេចរបស់ពួកគេ ធ្វើឲ្យមានការភ័ន្តច្រឡំ ហើយសម្រាប់អ្នកខ្លះទៀត ជម្រើសរបស់ពួកគេ ត្រូវបានរារាំងដោយអយុត្តិធម៌ដោយភាពលំអៀងរបស់គ្រូ

សិស្ស មកពីសហគមន៍ជនភាគតិច ទំនងជាបន្តការសិក្សាថ្នាក់ឧត្តមសិក្សា ច្រើនជាងមធ្យមភាគ របស់នូវែស៊ីឡង់ ។ ប៉ុន្តែសម្រាប់ ពួកគេមួយចំនួន ជម្រើសរបស់គាត់ ជួបប្រទះនូវឧបសគ្គ ។ ចំនួនសិស្ស មធ្យមសិក្សា ច្រើនជាង មួយក្នុងចំណោមសិស្សបួននាក់ មកពីសហគមន៍ជនភាគតិច និយាយថា អនុសាសន៍របស់គ្រូ សម្រាប់ឲ្យពួកគេ ជ្រើសរើសមុខវិជ្ជាសិក្សា គឺស្ថិតក្រោមឥទ្ធិពល ជនជាតិភាគតិច ។ ទាំងសិស្ស និងអ្នកមកពីសហគមន៍ជនជាតិភាគតិចមានការយល់ច្រឡំអំពី NCEA ។ ហើយសិស្សមួយភាគប្រាំ មិនគិតថា ពួកគេទទួលបានការគាំទ្រ ក្នុងការជ្រើសរើសមុខវិជ្ជាសិក្សា ឬជ្រើសរើសអាជីព ។

> *"ទម្លាប់ដែលគិតថាជនជាតិណាមួយ គួរប្រាថ្នារៀនឬធ្វើការអ្វីមួយ គឺនៅមានកម្រិតខ្លាំង ហើយក៏មិនអាចជួយឲ្យសិស្សឈានដល់ការប្រាថ្នារបស់ពួកគេបានឡើយ"* ។ (*អ្នកដឹកនាំសហគមន៍យុវជន*)

## តើសាលារៀនបំពេញតម្រូវការរបស់សិស្សមកពីសហគមន៍ជនជាតិភាគតិច និង whānau របស់ពួកគេយ៉ាងដូចម្តេច?

### 1. សាលារៀនមួយចំនួន មានការច្នៃប្រឌិត និងទទួលយកការអនុវត្តថ្មីៗរួចជាស្រេចហើយ ដើម្បីបំពេញតម្រូវការរបស់សហគមន៍ជនភាគតិច

ERO បានទៅទស្សនាសាលារៀន ហើយបានរកឃើញថា សាលាជាច្រើន បាន និងកំពុងសម្របតាមអ្វីដែលត្រូវបង្រៀន និងរបៀបបង្រៀន, ដោយបានភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ជនភាគតិច, និងបង្កើនការយល់ដឹងរបស់ពួកគេអំពីវប្បធម៌ និងតម្រូវការសិក្សា របស់សិស្សទាំងនោះ ។ ទោះជាយ៉ាងណាក៏ដោយ យើងក៏បានរកឃើញសាលារៀនមួយចំនួន កំពុងប្រឈមនឹងបញ្ហានៅពេលពួកគេព្យាយាមសម្របខ្លួន, មានសាលាខ្លះនៅមិនទាន់ទទួលយកការអនុវត្តថ្មីឡើយ, ហើយសាលាមួយចំនួន ក៏មិនដឹងប្រាកដដែរថា អ្វីដែលពួកគេ កំពុងធ្វើ វាអាចដើរទៅមុខរួចដែរឬទេ ។

### 2. ការយល់របស់គ្រូ អំពីសិស្សរបស់ខ្លួន បូករួមទាំងការយល់អំពីវប្បធម៌របស់សិស្ស គឺជាចំណុចសំខាន់នៃបទពិសោធន៍របស់សិស្សនៅសាលា តែស្ថានភាពនេះ ត្រូវតែកសាងជារូបរាងឡើង

ការយល់ដឹងរបស់គ្រូអំពីវប្បធម៌ គឺមិនស្របតាមការផ្លាស់ប្តូរចំនួនប្រជាជនរបស់យើងឡើយ ។ បុគ្គលិកបង្រៀនមិនឆ្លុះបញ្ចាំង ចំពោះជាតិពិន្ទុរបស់សិស្ស ។ ឧទាហរណ៍ មានគ្រូបង្រៀនត្រឹមតែ 5 ភាគរយប៉ុណ្ណោះជាជនជាតិអាស៊ី ។ Whānau និងសិស្ស មានការព្រួយបារម្ភអំពីកង្វះការយល់ដឹង និងការស្គាល់អំពីវប្បធម៌របស់សិស្សពីលោកគ្រូ អ្នកគ្រូ ។ របាយការណ៍អំពីគ្រូបានបញ្ជាក់ថា ពួកគាត់មានការយល់ដឹងតិចតួចអំពីវប្បធម៌ និងតម្រូវការសិក្សារបស់សិស្ស ។ គ្រូជាងពាក់កណ្តាលមិនមានការជឿជាក់ឡើយ ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយសិស្សមកពីសហគមន៍ជនភាគតិច ។ ពាក់កណ្តាលនៃសិស្ស ដែលមកពីសហគមន៍ជនជាតិភាគតិច បានរាយការណ៍ថា គ្រូបានសរសេរឈ្មោះរបស់ពួកគេខុស ។

## តើការអប់រំមានផលប៉ះពាល់យ៉ាងណាទៅថ្ងៃអនាគត?

នៅពេលដែលសាលារៀនរបស់ប្រទេសនូវែស៊ីឡង់ កាន់តែមានភាពចម្រុះជាតិសាសន៍ គឺនាំឲ្យមានឱកាសដ៏គួរឲ្យរំភើបមួយ សម្រាប់ពិនិត្យមើលការអប់រំឡើងវិញ រួមទាំងអ្វីដែលយើងបង្រៀន និងរបៀបដែលយើងបង្រៀនផងដែរ ។ យើងខ្ញុំបានកំណត់ពីផលប៉ះពាល់ធំៗចំនួនប្រាំ នៅពេលពិចារណាអំពីអនាគតនៃការអប់រំនៅ Aotearoa New Zealand ។

### 1. សាលារៀននីមួយៗត្រូវមានលទ្ធភាពឆ្លើយតបទៅនឹងការកើនឡើងនៃភាពចម្រុះជាតិសាសន៍

ភាពចម្រុះនៃជាតិសាសន៍ កំពុងកើនឡើងនៅទូទាំងប្រទេស - មិនត្រឹមតែនៅក្នុងទីក្រុង Auckland ប៉ុណ្ណោះទេ - ហើយការផ្លាស់ប្តូរដ៏ធំបំផុតគឺនៅក្នុងចំណោមមនុស្សវ័យក្មេង ។ ការកើនឡើងនៃភាពចម្រុះជាតិសាសន៍ នៅក្នុងសាលារៀនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការកើនឡើងនៃភាពចម្រុះនៃវប្បធម៌ និងភាពសម្បូរបែបនៃភាសាដែលពួកគេនិយាយ ។ សាលារៀននីមួយៗត្រូវតែអាចបំពេញតម្រូវការរបស់សិស្ស មកពីសហគមន៍ជនភាគតិច ដូច្នេះពួកគេមិនត្រឹមតែបន្តសម្រេចបាននូវការអប់រំប៉ុណ្ណោះទេ តែក៏ពេញចិត្តចំពោះសាលាផងដែរ ។

### 2. សាលានីមួយៗត្រូវតែអាចដោះស្រាយការរើសអើងជាតិសាសន៍

នៅ Aotearoa នូវែស៊ីឡង់ដ៏ មានសិស្សមកពីសហគមន៍ជនជាតិភាគតិច ជាច្រើន បានជួបប្រទះអំពើសម្លុតគម្រាមប្រកាន់ពូជសាសន៍ និងការលំអៀងដោយសារបញ្ហាពូជសាសន៍ ។ ហើយនៅពេលដែលពួកគេលើកឡើងពីការព្រួយបារម្ភ គឺសាលាមិនសូវអើពើប៉ុន្មានដែរ ។ យើងត្រូវធ្វើឲ្យបានល្អជាងមុន ។ សាលានីមួយៗត្រូវតែអាចទប់ស្កាត់ និងដោះស្រាយការរើសអើងជាតិសាសន៍ ។

### 3. យើងត្រូវតែធ្វើឲ្យបានល្អជាងមុនអំពីការផ្តល់សេវាអប់រំចំពោះសិស្សមកពីសហគមន៍ជនភាគតិច

យើងត្រូវស្វែងយល់បន្ថែមអំពីបទពិសោធន៍ការសិក្សា និងលទ្ធផលដែលសហគមន៍ជនជាតិចម្រុះចង់បាន ។ នេះអាចរួមបញ្ចូលប្រភេទ និងទីតាំងនៃសាលារៀន ព្រមទាំងមុខវិជ្ជាដែលបានបង្រៀន ។ យើងត្រូវតែបង្កើនសមត្ថភាពវប្បធម៌នៃកម្លាំងគ្រូបង្រៀន បច្ចុប្បន្ន និងអភិវឌ្ឍក្រុមគ្រូបង្រៀនដែលមានលក្ខណៈចម្រុះបន្ថែមទៀតសម្រាប់អនាគត ។

### 4. យើងត្រូវយល់កាន់តែច្បាស់អំពីបទពិសោធន៍ និងលទ្ធផលនៃការអប់រំ របស់សិស្សមកពីសហគមន៍ជនភាគតិច និងផ្តល់សម្លេងឱ្យពួកគេកាន់តែខ្លាំងក្នុងការអប់រំ

នៅឆ្នាំ 2043 សិស្សមួយភាគបួននឹងមកពីសហគមន៍ជនភាគតិច ។ សហគមន៍របស់ពួកគេគួរតែមានសិទ្ធិបញ្ចេញមតិបានច្រើន ចំពោះការអប់រំដែលពួកគេទទួលបាន ។ សិស្សរបស់យើងដែលមកពីសហគមន៍ជនភាគតិច និង whānau របស់ពួកគេ ជារឿយៗមិនសូវឃើញនៅក្នុងទិន្នន័យដែលយើងប្រមូលពីការងារអប់រំ, ការសន្ទនាអំពីការអប់រំ និងនៅក្នុងការសម្រេចចិត្តដែលយើងធ្វើឡើយ ។ យើងត្រូវស្វែងយល់ពីបទពិសោធន៍ និងលទ្ធផលរបស់ពួកគេ (ជាពិសេសថាតើស្ថានភាពរបស់សហគមន៍នីមួយៗ មានភាពខុសគ្នាបែបណា) និងផ្តល់ឱ្យសហគមន៍ជនភាគតិចនូវសំឡេងខ្លាំងជាងមុន ក្នុងការចូលរួមការងារអប់រំ ។

### 5. សម្រាប់អនាគតរបស់ Aotearoa New Zealand យើងត្រូវការ ការអប់រំ ដែលមានលក្ខណៈល្អ សម្រាប់សិស្សមកពីសហគមន៍ជនភាគតិច និង whānau របស់ពួកគេ

សិស្សានុសិស្ស និង whānau របស់ពួកគេ ដែលមកពីសហគមន៍ជនជាតិភាគតិច មានសេចក្តីប្រាថ្នាខ្ពស់សម្រាប់ការអប់រំ និងតម្លៃក្នុងការរក្សាភាសាកំណើតរបស់ពួកគេ ។ ការគាំទ្រសេចក្តីប្រាថ្នាទាំងនេះ និងធ្វើឱ្យការអប់រំរបស់ Aotearoa នូវែស៊ីឡង់ដ៏ មានភាពល្អសម្រាប់សិស្ស គ្រប់ជនជាតិ និងវប្បធម៌ នឹងជួយយើងបានក្នុងការពង្រឹងប្រព័ន្ធអប់រំ, កម្លាំងការងារ, វប្បធម៌ និងទំនាក់ទំនងជាមួយប្រទេសដទៃទៀត ។

## ចុះឥឡូវនេះ យើងត្រូវធ្វើអ្វី? វិស័យដែលត្រូវយកចិត្តទុកដាក់សម្រាប់អនាគត

សិស្សជាច្រើនមកពីសហគមន៍ជនជាតិភាគតិច កំពុងទទួលបានការអប់រំ ប៉ុន្តែពួកគេត្រូវយកឈ្នះលើអំពើរើសអើងជាតិសាសន៍ដែលរីករាលដាល, ភាពឯកោ, និងកង្វះការយល់ដឹងអំពីវប្បធម៌ ។ ដើម្បីរីកចម្រើនជាប្រទេសមួយ យើងត្រូវផ្លាស់ប្តូរ ។ មានវិស័យចំនួនប្រាំដែលមានឱកាសសម្រាប់ការផ្លាស់ប្តូរ ដើម្បីដើរទៅមុខ ។

1. **បញ្ចប់ការរើសអើងជាតិសាសន៍ ។** នៅពេលអនាគត យើងមានជម្រើសច្រើន ដើម្បីកំណត់ការរំពឹងទុកកាន់តែខ្លាំងលើការដោះស្រាយការរើសអើងជាតិសាសន៍ និងផ្តល់វិថីកាន់តែច្បាស់សម្រាប់ឪពុកម្តាយ និងសិស្ស ដើម្បីលើកឡើងពីការព្រួយបារម្ភ នៅពេលដែលការរើសអើងជាតិសាសន៍មិនត្រូវបានដោះស្រាយ ។ យើងក៏អាចមានការខិតខំប្រឹងប្រែងខ្លាំង ដើម្បីដោះស្រាយការរើសអើងជាតិសាសន៍ប្រឆាំងនឹងក្រុមជនងាយរងគ្រោះ ។
2. **ផ្លាស់ប្តូរអ្វីដែលត្រូវបង្រៀន ។** នៅពេលអនាគត អ្វីដែលត្រូវបង្រៀននៅក្នុងសាលា អាចត្រូវបានផ្លាស់ប្តូរ ដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែច្បាស់អំពីអ្វីដែលសហគមន៍ជនភាគតិចរបស់នូវែស៊ីឡង់ដ៏ និងសិស្ស មកពីសហគមន៍ទាំងនោះ ចង់បានពីការអប់រំ ។ នេះអាចរួមបញ្ចូលនូវការផ្លាស់ប្តូរភាសា ដែលត្រូវបង្រៀននៅក្នុងសាលា,

របៀបបង្រៀនអំពីសាសនា, ភាពសំខាន់របស់សហគមន៍ជនភាគតិច និងប្រវត្តិរបស់ពួកគេនៅក្នុងអ្វីដែលត្រូវបង្រៀន និងកម្រិតនៃភាពពិបាក ចំពោះកិច្ចការសាលា ។

3. **ផ្លាស់ប្តូររបៀបដែលត្រូវបង្រៀន (និងថាតើគ្រូជានរណា)** ។ នៅពេលអនាគត គ្រូបង្រៀននឹងចាំបាច់ត្រូវអាចយល់ និងអាចឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស ដែលមានលក្ខណៈចម្រុះជាតិសាសន៍ កាន់តែច្រើន ។ មានជម្រើសក្នុងការអភិវឌ្ឍន៍ជំនាញរបស់គ្រូទាំងអស់ និងផ្តល់ផ្លូវដែលជួយសមាជិកសហគមន៍ជនភាគតិចកាន់តែច្រើនក្នុងការបង្រៀន និងក្លាយជាជំនួយការគ្រូបង្រៀន ។
4. **ការផ្លាស់ប្តូរកន្លែងបង្រៀន (ពង្រីកជម្រើស)** ។ នៅពេលអនាគត សហគមន៍ជនភាគតិចអាចស្វែងរកសាលារៀនដែលត្រូវនឹងការរំពឹងទុករបស់ពួកគេសម្រាប់ការអប់រំ ។ មានយន្តការដែលមានស្រាប់ដើម្បីបង្កើតសាលា ដែលមានគុណតម្លៃ បុគ្គលិកលក្ខណៈ និងការរំពឹងទុកខុសគ្នា និងជម្រើសដើម្បីបង្កើនការគាំទ្រសម្រាប់សហគមន៍ ។
5. **បង្កើនភាពសំខាន់ និងសំឡេងរបស់សហគមន៍ជនភាគតិចក្នុងការអប់រំ** ។ ការរំពឹងទុកទៅថ្ងៃមុខ គឺមានជម្រើសក្នុងការប្រមូល និងតាមដានព័ត៌មានឱ្យបានហ្មត់ចត់បន្ថែមទៀតថាតើសិស្សទាំងនេះធ្វើបានល្អកម្រិតណា និងដើម្បីផ្តល់អាទិភាព និងជ្រើសរើសសហគមន៍ជនភាគតិច និងសិស្ស យ៉ាងសកម្មទៅក្នុងការគ្រប់គ្រងសាលារៀន ។

## សេចក្តីសន្និដ្ឋាន

AotearoaNew Zealand កំពុងក្លាយជាប្រជាជាតិដែលចម្រុះជាតិសាសន៍ កាន់តែខ្លាំង ។ ស្ថានភាពនេះ គឺជាការផ្តល់ឱកាសមួយសម្រាប់ប្រព័ន្ធអប់រំរបស់យើង ដើម្បីទទួលយកការផ្លាស់ប្តូរនេះ និងសម្របខ្លួន ដើម្បីឱ្យសិស្សមកពីសហគមន៍ជនភាគតិច និង whānau មានអនាគតល្អ ។ នៅឆ្នាំ 2043 មួយភាគបួននៃសិស្សរបស់យើងទាំងអស់នឹងមកពីសហគមន៍ជនភាគតិច ។ អ្វីដែលពួកគេចង់បានសម្រាប់ការអប់រំ គឺសំខាន់។

តាមរយៈការអប់រំដែលទទួលយកភាពចម្រុះ និងការបំពេញតម្រូវការរបស់សិស្សទាំងអស់ Aotearoa New Zealand នឹងកាន់តែរឹងមាំក្នុងសង្គម សេដ្ឋកិច្ច និងវប្បធម៌ ។ វាក៏នឹងក្លាយជាកន្លែងដ៏ទាក់ទាញសម្រាប់ប្រជាជនមកពីសហគមន៍ជនជាតិចម្រុះជាតិពិន្ទុ ក្នុងការរស់នៅ រៀន ធ្វើការ និងចិញ្ចឹមគ្រួសាររបស់ពួកគេ ។

**ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែមអំពីការសិក្សារបស់យើង អ្នកអាចអានរបាយការណ៍ពេញលេញ អំពី ៖**
ការអប់រំសម្រាប់កូនៗរបស់យើងទាំងអស់គ្នា ៖ ការទទួលយកជាតិសាសន៍ចម្រុះ

**សេចក្តីសង្ខេបនេះ ក៏មានជាភាសាដូចខាងក្រោមផងដែរ ៖** អង់គ្លេស, អារ៉ាប់, ចិន (សាមញ្ញ), ហិណ្ឌូ, ជប៉ុន, ខ្មែរ, កូរ៉េ, អេស្ប៉ាញ, តាកាឡុក, វៀតណាម ។

### អ្វីដែល ERO បានធ្វើ

ដើម្បីអាចយល់បានថាតើការអប់រំមានស្ថានភាពល្អកម្រិតណា ចំពោះសិស្សមកពីសហគមន៍ចម្រុះជាតិសាសន៍ យើងខ្ញុំបានប្រមូលព័ត៌មានដោយប្រើវិធីចម្រុះ ៖

- ការស្ទង់មតិអំពី whānau (អ្នកឆ្លើយតបចំនួន 1,250 នាក់) ដែលត្រូវបានសរសេរជា 10 ភាសា
- ការស្ទង់មតិរបស់សិស្ស (558) និងគ្រូបង្រៀន (263)
- ការទស្សនាសាលារៀនផ្ទាល់ចំនួនប្រាំបីនៅទូទាំង Aotearoa New Zealand
- 13 សហគមន៍hui/ក្រុមចំណាប់អារម្មណ៍
- សម្ភាសន៍ជាមួយអ្នកដឹកនាំសហគមន៍ ឬអ្នកដាក់ស្នើការចូលរួម ចំនួន 12 នាក់
- ដាក់ស្នើចំនួន 56
- ក្រុមផ្តោតអារម្មណ៍តាមអនឡាញ ជាមួយអ្នកដឹកនាំសាលាមកពីសាលាចំនួនប្រាំបី
- ទិន្នន័យដ៏ទូលំទូលាយ បានទទួលពីទីភ្នាក់ងារផ្សេងទៀត របស់រដ្ឋាភិបាល ។

### ការប្រឹក្សាសាធារណៈបានណែនាំយើង

ការសិក្សានេះ ត្រូវបានធ្វើឡើង ក្រោមមូលដ្ឋានសហគមន៍ជនជាតិភាគតិច ។ នៅខែមីនា ឆ្នាំ 2022 យើងខ្ញុំបានបោះពុម្ពផ្សាយឯកសារពិគ្រោះយោបល់ លើប្រធានបទស្តីពីការយល់ដឹងរយៈពេលវែង ហើយបានស្នើសុំការដាក់ស្នើ ។ នៅខែវិច្ឆិកា ឆ្នាំ 2022 យើងបានចេញផ្សាយរបាយការណ៍ព្រាងសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈ, held hui,

និងបានទទួលមតិកែលម្អជាលាយលក្ខណ៍អក្សរអំពីរបាយការណ៍ព្រាងនេះ ។
ឯកសារពិគ្រោះយោបល់ដំបូងមានជាប្រាំពីរភាសា ៖ អង់គ្លេស, តេរេអូ, អារ៉ាប់, ចិន (សាមញ្ញ), ហិណ្ឌូ, ជប៉ុន, កូរ៉េ, និងសេចក្តីសង្ខេបរបាយការណ៍ពង្រាង និងសំណួរពិគ្រោះយោបល់ដំណាក់កាលទី 2 មានជាភាសាអង់គ្លេស, អារ៉ាប់, ចិន (សាមញ្ញ), ហិណ្ឌូ, ជប៉ុន, ខ្មែរ, កូរ៉េ, អេស្ប៉ាញ, តាកាឡុក, វៀតណាម ។

យើងខ្ញុំសូមកោតសរសើរចំពោះការងាររបស់អ្នកទាំងអស់ ដែលបានគាំទ្រការស្រាវជ្រាវនេះ ជាពិសេសអ្នកសិក្សា ឪពុកម្តាយ និងជនជាតិដើមមកពីសហគមន៍ជនជាតិចម្រុះ អ្នកដឹកនាំសហគមន៍ និងគ្រូបង្រៀន និងអ្នកដឹកនាំមកពីសាលារៀន ដែលបានចែករំលែកជាមួយយើងនូវបទពិសោធន៍ ទស្សនៈ និងការយល់ដឹងរបស់ពួកគេតាមរយៈការសម្ភាសន៍ជាក្រុម។ ការពិភាក្សា និងការស្ទង់មតិ ។ បទពិសោធន៍របស់ពួកគេ គឺជាបេះដូងនៃអ្វីដែលយើងបានរៀន ។ យើងខ្ញុំសូមអរគុណចំពោះការលះបង់ពេលវេលារបស់អ្នក និងសម្រាប់ការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់អ្នកដោយបើកចំហ និងអស់ពីចិត្ត ។